# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីព្រះនាមរបស់ព្រះពុទ្ធមួយបទថា សម្មាសម្ពុទ្ធោ ប្រែថា ព្រះអង្គត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

**web site: hoksavann.org**

ថ្ងៃទី៧ តុលា ២០០៥

ពាក្យថាត្រាស់ដឹងដោយប្រពៃ បានសេចក្តីថា ត្រាស់ដឹងនូវអរិយសច្ចបួន ។ ការត្រាស់ដឹងនូវអរិយសច្ចបួន ទើបឈ្មោះថាត្រាស់ដឹងដោយប្រពៃ ព្រោះថា ការឃើញនូវអ្វីផ្សេងពីអរិយសច្ចបួន ពុំឈ្មោះថាឃើញដោយប្រពៃឡើយ ព្រោះមាគ៌ាក្រៅពីនេះពុំអាចធ្វើទុក្ខឲ្យអស់នៅឡើយ ។ ពាក្យថាចំពោះព្រះអង្គ បានសេចក្តីថា ត្រាស់ដឹងដោយការព្យាយាម និងពិសោធន៍ដោយខ្លួនព្រះអង្គឯង ពុំមែនត្រាស់ដឹងដោយឥទ្ធិពលខាងក្រៅ មានទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះញាតិ មិត្តភក្រ្ត ឬអ្នកដទៃណាមួយឡើយ ។

ពាក្យថា ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ បានសេចក្តីថា ព្រះអង្គរកឃើញផ្លូវត្រាស់ដឹង គឺមគ្គប្រកបដោយអង្គ៨ ពុំបានរៀនផ្លូវត្រាស់ដឹងនេះពីគ្រូណាឡើយ ។ មួយទៀតពុំមាន ជន គ្រូណា ត្រាស់ដឹងមុនព្រះអង្គ ហើយព្រះអង្គទៅរៀនពីគ្រូនោះឡើយ ឯតាបសទាំងពីរគឺ ឧទកតាបស និងអាឡារតាបស ដែលព្រះអង្គទៅរៀននោះ គឺរៀនបានត្រឹមផ្លូវសមាបត្តិប៉ុណ្ណោះ គឺគ្រូទាំង២ចេះតែផ្លូវឈាន ពុំមែនបង្រៀនផ្លូវត្រាស់ដឹងឡើយ ។ ប្រៀបដូចអ្នកវិទ្យាសាស្រ្តរកឃើញវិជ្ជាណាមួយមុនគេ, ព្រះពុទ្ធត្រាស់ដឹងមុនគេ ក៏ដូច្នោះដែរ ។

ការត្រាស់ដឹងរបស់ព្រះពុទ្ធនិងការរកឃើញរបស់អ្នកប្រាជ្ញក្នុងលោក មានលក្ខណ:ខុសគ្នា គឺអ្នកប្រាជ្ញផ្លូវលោករកឃើញវិជ្ជាផ្នែកណាមួយ តាមការពិសោធន៍ផ្លូវអាយតន: គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត និងកាយ ដោយប្រើប្រដាប់ជាឧបករណ៍ជាមួយផង ។ ឯការត្រាស់ដឹងរបស់ព្រះពុទ្ធ កើតឡើងពីបញ្ញាដ៏ជ្រាលជ្រៅដែលជា

លទ្ធផលចេញមក ពីការកសាងបារមីធម៌ ហើយជាជាតិទិបំផុតព្រះអង្គបានអប់រំព្រះទ័យតាមមគ្គប្រកបដោយអង្គ៨ មានព្រះទ័យបរិសុទ្ធ មានបញ្ញាញាណដ៏ជ្រាជ្រៅ ទើបឃើញការពិត គឺអរិយសច្ច៤ ដោយឧបករណ៍គឺវិបស្សនាញាណ ។ ការរកឃើញវិជ្ជាណាមួយរបស់ក្រុមអ្នកវិទ្យាសាស្ត្រ គ្រាន់តែជួយសំរួលដល់ការរស់នៅរបស់មនុស្សឲ្យបានប្រសើរប៉ុណ្ណោះ ប៉ុន្តែវិជ្ជាទាំងនោះ ពុំអាចធ្វើទុក្ខឲ្យអស់ទៅបានទេ ។ ចំណែកធម៌ដែលព្រះពុទ្ធត្រាស់ដឹង ទើបធ្វើឲ្យអ្នកប្រតិបត្តិតាមដល់នូវទីបំផុតទុក្ខ ។៚

★ ★

★